**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**

សេចក្តីប្រកាសព័ត៌មាន

# កម្ពុជា-ម៉ាឡេស៊ី ឯកភាពបន្តធ្វើឲ្យស៊ីជម្រៅបន្ថែមទៀតនូវ ទំនាក់ទំនងទ្វេភាគីដ៏យូរអង្វែង និងរឹងមាំលើគ្រប់វិស័យ

**រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែមីនា ឆ្នាំ២០២៣** - តបតាមការអញ្ជើញរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា **ឯកឧត្តម ដាតុ ស៊េរី អាន់វ៉ា ប៊ីន អ៊ីប្រាហ៊ីម** នាយករដ្ឋមន្ត្រីនៃប្រទេសម៉ាឡេស៊ី បានបញ្ចប់ដំណើរទស្សនកិច្ចផ្លូវការលើកដំបូង នៅព្រះរាជាណាចក្រកម្ពុជា នៅថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២៣ ក្នុងគោលបំណងបន្តធ្វើឲ្យស៊ីជម្រៅបន្ថែមទៀតនូវទំនាក់ទំនងទ្វេភាគីដ៏យូរអង្វែង និងរឹងមាំលើគ្រប់វិស័យ រវាងប្រទេសទាំងពីរ។

ក្នុងឱកាសទស្សនកិច្ចផ្លូវការរយៈពេល១ថ្ងៃនេះ **ឯកឧត្តម ដាតុ ស៊េរី អាន់វ៉ា ប៊ីន អ៊ីប្រាហ៊ីម** បានអញ្ជើញចូលក្រាបថ្វាយបង្គំគាល់**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា នៅព្រះបរមរាជវាំង។ ឯកឧត្តម ក៏បានអញ្ជើញជួបសម្តែងការគួរសមដាច់ដោយឡែក ជាមួយ**សម្តេចវិបុលសេនាភក្តី សាយ ឈុំ** ប្រធានព្រឹទ្ធសភា និង**សម្តេចអគ្គមហាពញាចក្រី ហេង សំរិន** ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា។

ក្នុងអំឡុងពេលកិច្ចប្រជុំទ្វេភាគី **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** បានជម្រាបជូនអំពីស្ថានភាពនយោបាយ និងសេដ្ឋកិច្ចរបស់កម្ពុជា រួមទាំងការត្រៀមរៀបចំកីឡាស៊ីហ្គេមលើកទី៣២ និងអាស៊ានប៉ារ៉ាហ្គេមលើកទី១២។ **ឯកឧត្តម ដាតុ ស៊េរី អាន់វ៉ា ប៊ីន អ៊ីប្រាហ៊ីម** បានកោតសរសើរ **សម្តេចតេជោនាយករដ្ឋមន្ត្រី** ចំពោះការដឹកនាំកម្ពុជា រួមទាំងការដោះស្រាយជម្លោះប្រកបដោយជោគជ័យ ការថែរក្សាសន្តិភាព និងការអភិវឌ្ឍ។

នាយករដ្ឋមន្ត្រីទាំងពីរបានបញ្ជាក់សាជាថ្មីនូវការប្តេជ្ញាបន្តជម្រុញកិច្ចសហប្រតិបត្តិការដែលផ្តល់ផលប្រយោជន៍ទៅវិញទៅមក លើគ្រប់វិស័យ រួមទាំងវិស័យពាណិជ្ជកម្មនិងវិនិយោគ ទេសចរណ៍ កសិកម្ម ការអភិវឌ្ឍធនធានមនុស្ស ថាមពលនិងការតភ្ជាប់ ការងារ ព្រមទាំងសន្តិសុខ និងការពារជាតិ។

នាយករដ្ឋមន្ត្រីទាំងពីរបានឯកភាពប្រគល់ភារកិច្ចជូនក្រសួងការបរទេសនៃប្រទេសទាំងពីររៀបចំឡើងវិញនូវកិច្ចប្រជុំលើកទី៣ នៃគណៈកម្មការចម្រុះកម្ពុជា-ម៉ាឡេស៊ី ឱ្យបានឆាប់តាមអាចធ្វើបាន ដើម្បីពិនិត្យមើលកិច្ចសហការបច្ចុប្បន្ន ស្វែងរកកិច្ចសហប្រតិបត្តិការក្នុងវិស័យថ្មី និងដាក់ចេញនូវវិធានការថ្មីៗ ដើម្បីពង្រឹងនិងពង្រីកភាពជាដៃគូបន្ថែមទៀត។

ចំពោះវិស័យពាណិជ្ជកម្ម និងវិនិយោគ នាយករដ្ឋមន្ត្រីទាំងពីរ បានកត់សម្គាល់ដោយក្តីពេញចិត្តចំពោះការកើនឡើងនៃទំហំពាណិជ្ជកម្មទ្វេភាគី និងទទួលស្គាល់នូវសក្តានុពលដ៏ធំធេងរវាងប្រទេសទាំងពីរ។ **សម្តេចតេជោនាយករដ្ឋមន្ត្រី** បានលើកទឹកចិត្តឱ្យធុរជនម៉ាឡេស៊ី ពិនិត្យលទ្ធភាពវិនិយោគក្នុងវិស័យអង្ករ គ្រាប់ស្វាយចន្ទី ទោចក្រយាន និងហាឡាល ដោយពិចារណាលើការអនុគ្រោះជាច្រើន ក្រោមច្បាប់ថ្មីស្តីពីការវិនិយោគ របស់កម្ពុជា។ **ឯកឧត្តម ដាតុ ស៊េរី អាន់វ៉ា ប៊ីន អ៊ីប្រាហ៊ីម** បានសន្យាលើកទឹកចិត្តធុរជនម៉ាឡេស៊ី ពិចារណាវិនិយោគលើផលិតផលនានានៅកម្ពុជារួមមានអង្ករ និងគ្រាប់ស្វាយចន្ទី ព្រមទាំងបានឯកភាពផ្តល់ការបណ្តុះបណ្តាល និងចែករំលែកបទពិសោធន៍ទាក់ទងនឹងវិស័យហាឡាលដល់កម្ពុជា ដើម្បីបង្កើនការនាំចេញទៅប្រទេសមូស្លីមនានាជាពិសេសតំបន់មជ្ឈឹមបូព៌ា។

ចំពោះវិស័យទេសចរណ៍ **សម្តេចតេជោនាយករដ្ឋមន្ត្រី**បានសង្កត់ធ្ងន់អំពីសារសំខាន់នៃជើងហោះហើរត្រង់ និងការអនុវត្តប្រកបដោយប្រសិទ្ធិភាពនូវអនុស្សរណៈនៃការយោគយល់គ្នា ស្តីពីកិច្ចសហប្រតិបត្តិការលើវិស័យទេសចរណ៍ ដែលត្រូវបានចុះហត្ថលេខាកាលពីឆ្នាំ២០១៩ និងបានស្នើម៉ាឡេស៊ីផ្តល់ជំនួយបច្ចេកទេសក្នុងវិស័យហាឡាល ក្នុងគោលដៅទាក់ទាញនិងទទួលភ្ញៀវទេសចរមូស្លីមមកកម្ពុជា ឱ្យកាន់តែបានច្រើនថែមទៀត។

ពាក់ព័ន្ធនឹងវិស័យកសិកម្ម នាយករដ្ឋមន្ត្រីទាំងពីរបានលើកទឹកចិត្តឱ្យមានការអនុវត្តប្រកបដោយប្រសិទ្ធភាពនូវអនុស្សរណៈនៃការយោគយល់គ្នាចំនួន២ស្តីពី កិច្ចសហប្រតិបត្តិការក្នុងឧស្សាហកម្មឬស្សី និងវិស័យកសិកម្ម។ **ឯកឧត្តម ដាតុ ស៊េរី អាន់វ៉ា ប៊ីន អ៊ីប្រាហ៊ីម** បានកោតសរសើរកម្ពុជា ចំពោះអតិរេកអង្ករ និងសន្យាលើកទឹកចិត្តក្រុមហ៊ុនម៉ាឡេស៊ី ពិចារណានាំចូលអង្ករកម្ពុជាទៅកាន់ម៉ាឡេស៊ី។

ពាក់ព័ន្ធនឹងការអភិវឌ្ឍធនធានមនុស្ស **សម្តេចតេជោនាយករដ្ឋមន្ត្រី** បានសម្តែងអំណរគុណចំពោះម៉ាឡេស៊ីដែលបានផ្តល់វគ្គបណ្តុះបណ្តាលសម្រាប់មន្ត្រីរាជការកម្ពុជាតាមរយៈកម្មវិធីកិច្ចសហប្រតិបត្តិការបច្ចេកទេសម៉ាឡេស៊ី (MTCP) និងកម្មវិធីកិច្ចសហប្រតិបត្តិការការពារជាតិម៉ាឡេស៊ី (MDCP) និងបានស្នើម៉ាឡេស៊ី ឱ្យចែករំលែកបទពិសោធន៍អំពីសេដ្ឋកិច្ចឌីជីថល។

តបតាមសំណើរបស់ភាគីកម្ពុជា **ឯកឧត្តម ដាតុ ស៊េរី អាន់វ៉ា ប៊ីន អ៊ីប្រាហ៊ីម** បានសន្យាជួយសម្របសម្រួលការស្ថាបនាខ្សែកាប្លិ៍អគ្គិសនីតាមបាតសមុទ្រ ឆ្លងកាត់ដែនសមុទ្រប្រទេសម៉ាឡេស៊ី ដែលជាផ្នែកមួយនៃគម្រោងពាណិជ្ជកម្មថាមពលបៃតងរវាងកម្ពុជា និងសិង្ហបុរី។

ចំពោះវិស័យការងារ តបតាមសំណើរបស់**សម្តេចតេជោនាយករដ្ឋមន្ត្រី** ក្នុងការសម្របសម្រួលពលករកម្ពុជា **ឯកឧត្តម ដាតុ ស៊េរី អាន់វ៉ា ប៊ីន អ៊ីប្រាហ៊ីម** បានបញ្ជាក់ថា ម៉ាឡេស៊ីអនុញ្ញាតឱ្យពលករដែលស្នាក់នៅហួសពេលកំណត់ មកចុះឈ្មោះរហូតដល់ចុងឆ្នាំ២០២៣ ដើម្បីបន្តធ្វើការនៅម៉ាឡេស៊ី។ **សម្តេចតេជោនាយករដ្ឋមន្ត្រី** ក៏បានស្នើឲ្យមានការទទួលស្គាល់លើឯកសារធ្វើដំណើររបស់ពលករកម្ពុជាផងដែរ។

ពាក់ព័ន្ធនឹងវិស័យការពារជាតិ និងសន្តិសុខ **ឯកឧត្តម ដាតុ ស៊េរី អាន់វ៉ា ប៊ីន អ៊ីប្រាហ៊ីម** បានសម្តែងអំណរគុណចំពោះអាជ្ញាធរកម្ពុជា ដែលបានជួយសង្គ្រោះពលរដ្ឋម៉ាឡេស៊ី ពីបណ្តាញក្រុមឆបោកការងារ។ គំនិតផ្តួចផ្តើមមួយចំនួនត្រូវបានលើកយកមកពិភាក្សា ដើម្បីរួមគ្នាប្រយុទ្ធប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែន រួមមានការរត់ពន្ធមនុស្ស និងការលាងលុយកខ្វក់។

នាយករដ្ឋមន្ត្រីទាំងពីរបានផ្លាស់ប្តូរទស្សនៈគ្នាលើបញ្ហាតំបន់ និងអន្តរជាតិ និងបានឯកភាពផ្តល់នូវការគាំទ្រគ្នាទៅវិញទៅមក នៅក្នុងក្របខណ្ឌពហុភាគី រួមមានអង្គការសហប្រជាជាតិ និងអង្គការស្តីពី កិច្ចសហប្រតិបត្តិការឥស្លាម។ **ឯកឧត្តម ដាតុ ស៊េរី អាន់វ៉ា ប៊ីន អ៊ីប្រាហ៊ីម** បានអបអរសាទរ កម្ពុជាចំពោះជោគជ័យនៃការធ្វើជាប្រធានអាស៊ានកាលពីឆ្នាំមុន និងបានសង្កត់ធ្ងន់ថា ប្រទេសសមាជិកអាស៊ានដទៃទៀត ដែលឯកឧត្តមបានអញ្ជើញបំពេញទស្សនកិច្ចកន្លងទៅ បានធ្វើការវាយតម្លៃដូចគ្នាថា កម្ពុជាបានបំពេញការងារយ៉ាងល្អប្រសើរក្នុងការពង្រឹងអាស៊ាន ទោះបីជាតួនាទីនេះមានការលំបាកជាច្រើនក៏ដោយ។ លើសពីនេះ **ឯកឧត្តម ដាតុ ស៊េរី អាន់វ៉ា ប៊ីន អ៊ីប្រាហ៊ីម** បានកោតសរសើរកម្ពុជា ដែលគោរពជនជាតិភាគតិច រួមទាំងសហគមន៍មូស្លីមផងដែរ។

នាយករដ្ឋមន្ត្រីទាំងពីរក៏បានធ្វើជាសាក្សីក្នុងពិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នាចំនួនពីរ ស្តីពីការជ្រើសរើស ការប្រើប្រាស់ និងការធ្វើមាតុភូមិនិវត្តន៍របស់ពលករ និងពលករការងារផ្ទះ។

ក្នុងថ្ងៃដដែលនោះ **ឯកឧត្តម ដាតុ ស៊េរី អាន់វ៉ា ប៊ីន អ៊ីប្រាហ៊ីម** ក៏បានចូលរួមជាមួយ**សម្តេចតេជោនាយករដ្ឋមន្ត្រី** ក្នុងពិធីលៀងសាយភោជន៍ស្រាយបួសរបស់សាសនិកអ៊ីស្លាម និងចូលរួមពិធីថ្វាយបង្គំព្រះ ជាមួយបញ្ញវន្តមូស្លីម និងសហគមន៍មូស្លីមនៅកម្ពុជា ផងដែរ។

**សម្តេចតេជោនាយករដ្ឋមន្ត្រី** បានទទួលដោយសេចក្តីសោមនស្សរីករាយ នូវការអញ្ជើញទៅបំពេញទស្សនកិច្ចផ្លូវការ នៅម៉ាឡេស៊ីរបស់**ឯកឧត្តម ដាតុ ស៊េរី អាន់វ៉ា ប៊ីន អ៊ីប្រាហ៊ីម** នៅពេលវេលាសមស្រប៕